**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៣៥៥ សសរ

# សេចក្តីសំរេច
## ស្តីពីការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

**សំរេច**

**ប្រការ ១ :** ត្រូវបានផ្ទេរសិទ្ធិជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចការងារ និងចូលរួមបើកការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើក ទី២៥ នៅទីក្រុងវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចាប់ពីថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០០៩ រហូតដល់ពេលសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តន៍មកកាន់មាតុប្រទេសវិញ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលរាជធានី អភិបាល គ្រប់ខេត្ត និងឯកឧត្តម ស ខេង ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ ២
- -ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com